**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំ៩ខែ ដើមឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងរយៈពេល៩ខែ ដើមឆ្នាំ២០១៥នេះ ដំណើរការនៃការងារបង្កបង្កើនផលស្រូវរដូវវស្សានៅទូទាំងប្រទេស សម្រេចបានចំនួន២.៤៤៦.៧៥៥ហិកតា ស្មើនឹង៩៥,៣១% នៃផែនការ២.៥៦៧.១៣០ហិកតា (លើសឆ្នាំមុន២៦.៣០៦ ហិកតា គិតក្នុងរយៈពេលដូចគ្នា)។ ខេត្តចំនួន១០ ត្រូវបានបញ្ចប់ការងារដាំដុះស្រូវរដូវវស្សាហើយ គឺខេត្តបន្ទាយមានជ័យ កោះកុង មណ្ឌលគិរី ព្រះវិហារ សៀមរាប ព្រះសីហនុ ស្ទឹងត្រែង ឧត្តរមានជ័យ កែប និងប៉ៃលិន។ មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយល្អនៅទូទាំងប្រទេស តែនៅតាមតំបន់ខ្លះក៏ពុំទាន់មានទឹកដក់គ្រប់គ្រាន់នៅឡើយ ដោយសារភ្លៀងធ្លាក់នៅចុងរដូវ។ ឆ្នាំនេះ ប្រជាកសិករចូលចិត្តបង្កបង្កើនផលស្រូវ ដោយព្រោះយកតែម្តង(ប្រមាណ៨៣%) ច្រើនជាងការដកស្ទូង(ប្រមាណ១៧%) ម្យ៉ាងមកពីការរាំងស្ងួតអូសបន្លាយយូរនៅដើមរដូវ និងដោយសារខ្វះកម្លាំងពលកម្មផងដែរ។

ដោយឡែកចំពោះការឆ្លងរាលដាលជំងឺជ្រូកត្រចៀកខៀវមកទល់ពេលនេះ ស្ថានភាពជំងឺស្ទើរតែបាត់ទាំងស្រុងហើយ។ ទោះជាយ៉ាងណា ក្រសួងនៅតែបន្តចាត់វិធានការតាមគ្រប់រូបភាពដើម្បីទប់ស្កាត់យ៉ាងយកចិត្តទុកដាក់ ដូចជាធ្វើការផ្សព្វផ្សាយណែនាំដល់កសិករ ភ្នាក់ងារសុខភាពសត្វភូមិ និងអាជ្ញាធរភូមិ-ឃុំ អំពីផលប៉ះពាល់នៃជំងឺឆ្លងសត្វ វិធានការការពារ និងផ្តល់ព័ត៌មានពីសត្វឈឺឬងាប់នៅក្នុងមូលដ្ឋានដែលផ្ទុះជំងឺដល់មន្ត្រីបសុពេទ្យស្រុក-ខេត្ត ឬតាមរយៈប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍របស់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ដើម្បីចុះអន្តរាគមន៍ទាន់ពេលវេលា។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មដែលសម្រេចបានក្នុង៩ខែ ដើមឆ្នាំ២០១៥នេះ មានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ លទ្ធផលការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៥

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន៣.៤២៦.៨៦៤ហិកតា ក្នុងនោះភ្ជួររាស់ដោយគោ ក្របីចំនួន៤០៦.៦០៦ហិកតា ស្មើនឹង១១,៨៧% និងគ្រឿងយន្តចំនួន៣.០២០.២៥៨ហិកតា ស្មើនឹង៨៨,១៣% លើសឆ្នាំមុនចំនួន៥៨៦.០១៧ហិកតា
- ផ្ទៃដីសាបសម្រេចបានចំនួន៦៩.៨២៥ហិកតា តិចជាងឆ្នាំមុនចំនួន៤៣.១៦៤ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសម្រេចបានចំនួន២.៤៤៦.៧៥៥ហិកតា ស្មើនឹង៩៥,៣១% នៃផែនការ២.៥៦៧.១៣០ ហិកតា លើសឆ្នាំមុនចំនួន២៦.៣០៦ហិកតា ក្នុងនោះស្រូវពង្រោះនិងស្រូវចម្ការ២.០៤៣.៥៤១ហិកតា ស្មើនឹង៨៣,៥២% ស្រូវសន្ទូងមាន៤០៣.២១៤ហិកតា ស្មើនឹង១៦,៤៨% នៃផ្ទៃដីអនុវត្ត២.៤៤៦.៧៥៥ហិកតា និងស្រូវតាមប្រភេទមាន៖
  + ស្រូវស្រាលចំនួន៥៤២.៧៣១ហិកតា (ក្នុងនោះ ស្រូវបង្កើនរដូវចំនួន១៣៥.៣០១ហិកតា) តិចជាងឆ្នាំមុនចំនួន៦៦.០០៦ហិកតា
  + ស្រូវកណ្តាលចំនួន១.២៥៨.៥២៤ហិកតា លើសឆ្នាំមុនចំនួន៧១.៨៦៦ហិកតា
  + ស្រូវធ្ងន់ចំនួន៥៥៩.០០៨ហិកតា លើសឆ្នាំមុនចំនួន៣០.៥១២ហិកតា

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

+ ស្រូវចម្ការចំនួន៣៩.៧១៩ហិកតា តិចជាងឆ្នាំមុនចំនួន៤.៣៥៨ហិកតា

+ ស្រូវឡើងទឹកចំនួន៤៦.៧៧៣ហិកតា តិចជាងឆ្នាំមុនចំនួន៥.៧០៨ហិកតា។

**១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម**

- ផ្ទៃដីដំណាំរួមផ្សំសម្រេចបានចំនួន៧៣៧.៩០៧ហិកតា ស្មើនឹង១៣១,៨៧% នៃផែនការ៥៥៩.៥៥៩ហិកតា លើសឆ្នាំមុនចំនួន៥៦.៤០ហិកតា

- ផ្ទៃដីដំណាំឧស្សាហកម្មសម្រេចបានចំនួន១១៦.៩០៥ហិកតា ស្មើនឹង៩០,១១% នៃផែនការ១២៩.៧៤២ហិកតា តិចជាងឆ្នាំមុនចំនួន១១.០០៦ហិកតា។

**១.៣ ល្បឿនការងារប្រមូលផលស្រូវស្រាលដើមរដូវវស្សាឆ្នាំ២០១៥**

ការងារប្រមូលផលស្រូវស្រាលដើមរដូវសម្រេចបានចំនួន១៤៧.៩០០ហិកតា លើផ្ទៃដីអនុវត្តស្រូវស្រាលសរុបចំនួន ៥៥៧.៨៤០ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន៥៣៥.១៥៧តោន តិចជាងឆ្នាំមុន១៥៩.៤៥៧តោន និង ទិន្នផលជាមធ្យមចំនួន៣,៦៣១តោនក្នុងមួយហិកតា តិចជាងឆ្នាំមុន១៩៣គីឡូក្រាមក្នុងមួយហិកតា។

**១.៤ ការនាំចេញអង្ករ**

គួរកត់សម្គាល់ថា ការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល៩ខែដើមឆ្នាំ២០១៥នេះ មានបរិមាណចំនួន៣៦៩.១០៥ តោន ដែលមានការកើនឡើងចំនួន៩៩.៧៣៥តោន(+៣៧%) លើសបរិមាណនាំចេញក្នុងរយៈពេល៩ខែដើមឆ្នាំ២០១៤ (ដែលមានតែ២៦៩.៣៧០តោន)។ ដោយឡែកបរិមាណអង្ករនាំចេញក្នុងខែកញ្ញា ឆ្នាំ២០១៥នេះ មានតែ២៦.៩៦៩តោន ដែលមានការថយចុះចំនួន៨.៥៤២តោន(-៣១,៧%)តិចជាងបរិមាណនាំចេញក្នុងខែកញ្ញា ដើមឆ្នាំ២០១៤ ដែលមាន ៣៥.៥១១តោន និងនាំចេញទៅកាន់ទិសដៅចំនួន៥៥ប្រទេស។

**១.៥ ស្ថានភាពប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិ**

គ្រោះខ្វះទឹកប៉ះពាល់លើផ្ទៃដីសរុបចំនួន២៣៤.៦៩៥ហិកតា ក្នុងនោះមានសំណាបសរុបចំនួន២.៥៩៦ហិកតា និងសន្ទូង-ពង្រោះសរុបចំនួន២៣២.០៩៩ហិកតា។ សំណាបខូចខាតចំនួន៦៤ហិកតា សន្ទូង-ពង្រោះខូចខាតចំនួន ១៥.៨៩០ហិកតា។

| ល.រ | រាជធានី-ខេត្ត | ប៉ះពាល់(ហត) | | ផ្ទៃដីខូចខាតជាក់ស្តែង(ហត) | |
|---|---|---|---|---|---|
| | | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ |
| ១ | បន្ទាយមានជ័យ | 26 | 85,592 | - | 2,485 |
| ២ | បាត់ដំបង | - | 64,828 | - | 13,033 |
| ៣ | កំពង់ចាម | 87 | 3,755 | - | - |
| ៤ | កំពង់ឆ្នាំង | 487 | 2,920 | - | 88 |
| ៥ | កំពង់ស្ពឺ | 1,712 | 3,813 | 64 | - |
| ៦ | កំពង់ធំ | - | 6,470 | - | - |
| ៧ | កណ្តាល | 245 | 1,175 | - | - |
| ៨ | ភ្នំពេញ | - | 170 | - | - |
| ៩ | ព្រៃវែង | 15 | 2,513 | - | - |
| ១០ | ពោធិ៍សាត់ | - | 24,387 | - | 163 |
| ១១ | ស្វាយរៀង | - | 10,265 | - | - |
| ១២ | តាកែវ | 10 | 13,638 | - | |
| ១៣ | ឧត្តរមានជ័យ | - | 12,027 | - | - |
| ១៤ | សៀមរាប | - | 150 | - | |

| | | | | | |
|---|---|---|---|---|---|
| ១៥ | ប៉ៃលិន | - | *166* | - | *121* |
| ១៦ | ក្រចេះ | *14* | *230* | - | - |
| **សរុប** | | ***2,596*** | ***232,099*** | ***64*** | ***15,890*** |

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៥-២០១៥(ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥០៧,៥១ | ៤០៨,២១ | ៤៨៨,៥៩ | ៣៤៩,០០ |
| **សរុប I** | | **៥០៧,៥១** | **៤០៨,២១** | **៤៨៨,៥៩** | **៣៤៩,០០** |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១១.៦១៨,៣៧ | ៤.៤០៩,៤៤ | ១៤.៤០៦,៣៤ | ១១.៤៥៧,២២ |
| ២ | ក្រុមហ៊ុន ស៊ីហ្វវ៉ាប់ប៊ើលីមីធីត (រតនគិរី) | ៧៨,៥៣ | ២.០៦៤,៣០ | ២៥៨,៣៧ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ១.០៥៧,១២ | ៧៩២,៨៣ | ៥៨១,៦០ |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ២.៦៤៥.៩៧ | ៣.០៦៥,៣៨ | ៤.៨០៩,៦៥ | ៣.៩៣១,៨៤ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.៣៤៦,៦៩ | ២.៦៨៨,៤៩ | ១.៧៨៩,៩២ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វវីសេសស (ស្នួល) | ១.៧៤៤,៧៨ | ២.៦៤១,៤៣ | ១.៥៨១,៣២ | ១.២៣០,០០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.០២៩,៧០ | ១.២៣៧,៥៩ | ៩៥៩,៤០ | ៥២៥,២០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣.១១១,៦៥ | ១.២១៥,៥៥ | ១.២១១,៦២ | ៨៧៤,៨០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ៨៧៥,៦៦ | - | - |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.២៥៦,០៩ | ២.៤៧៥,៣៨ | ៣.៨១៦,៨៨ | ២.៩៩៩,៤០ |
| **សរុប II** | | **២៨.៩៩៥,៦៣** | **២៤.៣៨៨,៥៤** | **៣០.៥២៤,៩០** | **២៣.៣៨៩,៩៨** |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៦.៤១៥,០០ | ១៥៥.២៦២,០០ | ៣.១១៨,៥០ | ៣.១១៨,៥០ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៧៣.៣៩៦,០០ | ៦៦.៩៥០,០០ | ៤៩.១៣២,៨៧ | ៤៧.៩៣២,៨៧ |
| **សរុប III** | | **៧៩.៨១១,០០** | **២២២.២១២,០០** | **៥២.២៥១,៣៧** | **៥១.០៥១,៣៧** |
| **សរុប I+II+III** | | **១០៩.៣១៤,១៤** | **២៤៧.០០៨,៧៥** | **៨៣.២៦៤,៨៦** | **៧៤.៧៩០,៣៥** |

- គួរកត់សម្គាល់ថា ក្នុងខែកញ្ញា ឆ្នាំ២០១៥នេះ តម្លៃកៅស៊ូជាមធ្យមគឺ១.២១៥ ដុល្លារក្នុងមួយតោន។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ចូលរួមកិច្ចប្រជុំលើកទី១៣ និងទី១៤ របស់ក្រុមប្រឹក្សាស្តង់ដារជាតិនៅវិទ្យាស្ថានស្តង់ដារកម្ពុជានៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម

- បើកវគ្គបណ្តុះបណ្តាលបាន៨វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន២១៣នាក់ មកពីបណ្តាខេត្ត និងក្រុមហ៊ុនចម្ការកៅស៊ូ

- បញ្ជូនមន្ត្រីជំនាញនិងថ្នាក់ដឹកនាំចំនួន៨រូប ទៅចូលរួមក្នុងកិច្ចប្រជុំនិងសិក្ខាសាលានៅប្រទេសម៉ាឡេស៊ី និងប្រទេសថៃ

- ផ្តល់មែកពូជចំនួន១៥ក្លូន ស្មើ១.២៣២ម៉ែត្រ សម្រាប់បំប៉ៅដើម្បីដាំផ្ទុសឡូតិ៍ពិសោធន៍ក្លូន PVAA01-PVAA 02 នៅក្រុមហ៊ុនចម្ការកៅស៊ូ ទ្រីភាពបឹងទន្លេប្រេច ស្រុករវៀង ខេត្តព្រះវិហារ/

- ដឹកនាំនិស្សិតសរសេរសារណាបទថ្នាក់បរិញ្ញាបត្រចំនួន១៥នាក់ មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យស្វាយរៀង និងសាលាជាតិកសិកម្មកំពង់ចាម និងប្រគល់វិញ្ញាបនបត្រច្បារពូជកៅស៊ូដល់ម្ចាស់ច្បារពូជកៅស៊ូបាន០១កន្លែង នៅខេត្តសៀមរាប

- ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍ជាមួយ IRA លើកទី១១២ និងធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុកលើកទី៤០,៤១និង៤២ ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍ក្នុងស្រុកសម្រាប់ការទទួលស្គាល់ជាផ្លូវការពីវិទ្យាស្ថាន

- បង្កើតចម្ការពិសោធន៍ជីចំនួន៤ក្នុងឆ្នាំ២០១៥ លើក្លូន GT1,PB217,PB260 និងRRIM712 លើប្រភេទជីគីមី NPK15.15.15 និង NPK15.7.18។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

**៣.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ការចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត ការរៀបចំឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្តនិងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

- **ការងារកែលម្អពូជ៖** ការកែលម្អពូជកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរ ព្រោះប្រជាកសិករភាគច្រើនកាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។

- **ការងារឡជីវឧស្ម័ន៖** ដោយមានការអភិវឌ្ឍផ្នែកចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយការអនុវត្តល្អប្រសើរការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននឹងកំពុងអនុវត្តន៍យ៉ាងសកម្មដែលមកទល់ពេលនេះ ខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់សម្រេចបាន១.៣៨១ឡ (គិតពីខែមករា-សីហា ឆ្នាំ២០១៥) និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបាន១២០ឡ (គិតត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤) សរុបរួម: ១.៥០១ឡ។

- **ចំណីសត្វ៖** បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។

- **ការងារដំណាំចំណីសត្វ៖** តាមបណ្តាខេត្តមួយចំនួនបានធ្វើសួនដំណាំចំណីសត្វ ការផ្សព្វផ្សាយអំពីអត្ថ-ប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការជាមួយគម្រោងអន្តរជាតិដូចជា ACIAR និងCIAT ជាដើម។

### ៣.២ ការងារបសុព្យាបាល

- លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖

ចំពោះជំងឺជ្រូកត្រចៀកខៀវ (Porcine Reproductive Respiratory Syndrome: PRRS) ដែលបានកើតមានឡើងនៅខេត្តសៀមរាប កំពង់ចាម ព្រៃវែង និងខេត្តស្វាយរៀងនោះ ក្រសួងបានចេញប្រកាសកំណត់តំបន់ផ្ទុះជំងឺនិងបានចាត់អង្គភាពជំនាញនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលសហការជាមួយមន្ត្រីបសុពេទ្យខេត្ត ស្រុកនិងអាជ្ញាធរថ្នាក់ក្រោមជាតិដើម្បីបន្តចាត់វិធានការជីវសុវត្ថិភាព និងតាមដានត្រួតពិនិត្យនៅតាមតំបន់ដែលផ្ទុះជំងឺព្រមទាំងធ្វើអនាម័យសត្វនិងសាច់តាមបណ្តាសត្តឃាតដ្ឋានយ៉ាងយកចិត្តទុកដាក់ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៅកន្លែងដ៏ទៃទៀត។ មកទល់ពេលនេះស្ថានភាពជំងឺស្ទើរតែបាត់ទាំងស្រុងហើយ។

ខេត្ត-រាជធានីចំនួន២៣ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគនៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វចំនួន១៨.៩២៨លើក។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយបានកប់និងកម្ទេចចោលផលិតផលសាច់ខូចគុណភាពតាមវិធានបសុពេទ្យចំនួន៨៤១,៦០គីឡូក្រាម រឹបអូសផលិតផលសត្វខូចគុណភាព(ក្រលៀនសត្វ)សរុបចំនួន១.៤៤០គូ បង្ក្រាបបទល្មើសអាជីវកម្មខុសច្បាប់ចំនួន៣៩ករណី និងធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន៤១.១០០.០០០រៀល។

• **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត និងចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស។

• **ការងារនីតិកម្មនិងវិវាទ៖** សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានកែសម្រួលជាស្ថាពរ និងគ្រោងដាក់ក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាពេលដ៏ខ្លីខាងមុខនេះ។ បន្តរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងការគ្រប់គ្រងសត្តឃាតដ្ឋាន ព្រមទាំងរៀបចំផែនការយុទ្ធសាស្ត្រវិស័យសុខភាពសត្វនិងផលិតកម្មសត្វរយៈពេល១០ឆ្នាំ (២០១៥-២០២៤)។

### ៣.៣ ការងារស្រាវជ្រាវ៖

• **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន ១៥៥ក្បាល ក្នុងនោះគោបា៣ក្បាល គោប្រាម៉ាន់កាត់៣៤ក្បាល គោជំទង់៣៤ក្បាល គោបៅដោះ៤២ក្បាល គោកំផែងសែន៤២ក្បាល គោកើតថ្មី២០ក្បាល គោលក់១៦ក្បាល និងគោងាប់ចំនួន១ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប២៥៩ក្បាល ក្នុងនោះជ្រូកបាចំនួន៨ក្បាល ជ្រូកមេ៨៦ក្បាល កូនជ្រូក១៦៥ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតី និងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

• **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាន និងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ ដើម្បីវិភាគរកប្រភេទមេរោគបង្កជំងឺជាពិសេសមេរោគជំងឺផ្តាសាយបក្សី មេរោគជ្រូកត្រចៀកខៀវជាដើម។ ជាក់ស្តែងក្នុងរយៈពេល៩ខែ ដើមឆ្នាំ២០១៥នេះ វិទ្យាស្ថានស្រាវជ្រាវបសុព្យាបាលបានពិនិត្យវត្ថុវិភាគសរុបចំនួន២.៩០២ករណី។

**៣.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី ជំងឺជ្រូកត្រចៀកខៀវ និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

- ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤កន្លែង (អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង កំពង់ធំ និងសៀមរាប) ដែលមានសត្វស្លាបប្រមាណ២០៤ប្រភេទ (ប្រហែល៤៨.៥៩៦ក្បាល)

- ប្រមូលសំណាកសត្វប្រចៀវ និងជ្រើងសរុបចំនួន៣៣៧ក្បាល (ក្នុងនោះមានសត្វជ្រើងចំនួន៣៧ក្បាល) ដើម្បីធ្វើការពិនិត្យទៅលើការបន្តពូជ ការកំណត់អត្តសញ្ញាណ និងយកទឹកនោម ទឹកមាត់ ឈាម លាមក ដើម្បីធ្វើការពិនិត្យនិងវិភាគរកមេរោគ

- ប្រមូលសំណាកសត្វព្រៃចំនួន២.៥៦៣សំណាក ក្នុងចំណោមសត្វព្រៃ៣១១ក្បាល ដើម្បីធ្វើការវិភាគរកជំងឺដែលមានប្រភពពីសត្វព្រៃ

- ផ្តល់ចំណីដល់សត្វត្មាតនៅស្ទឹងត្រែង ក្រចេះ និងព្រៃការពារព្រះវិហារ ដោយរាប់ឃើញត្មាតសរុបប្រមាណ១០៧ក្បាល ដើម្បីធានាការរស់រានរបស់សត្វត្មាត និងធ្វើការអង្កេតតាមដាន

- ការពារសម្បុកសត្វត្រយ៉ងចង្កំ ក ស ចំនួន២៦សម្បុក ត្រដក់តូចចំនួន៣២សម្បុក រំពេរទន្លេចំនួន១៨សម្បុក នៅខេត្តស្ទឹងត្រែង និងក្រចេះ និងព្រៃការពារព្រះវិហារ។ មូលហេតុដែលត្រូវការពារសម្បុកសត្វគឺដើម្បីធានាសុវត្ថិភាពពង កូន ព្រោះប្រភេទសត្វទាំងនេះមានមាឌធំងាយស្រួលក្នុងការចាប់យកកូន ឬប្រមូលយកពងពីសំណាក់ប្រជាជនមូលដ្ឋាន ហើយសត្វស្លាបប្រភេទនេះជិតផុតពូជនិងមានដោយកម្រ

- កំពុងរៀបចំអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃព្រះរការ ដែលមានទំហំ ៩២.១៣២ហិកតា ក្នុងខេត្តព្រះវិហារ

- រៀបចំផែនការគ្រប់គ្រងតំបន់ព្រៃការពារមណ្ឌលគិរី

- មានភ្ញៀវទេសចរណ៍បរទេសចំនួន១.៣៥០នាក់ មកទស្សនាតំបន់អភិរក្សជីវចម្រុះវ៉ឺនសៃ-សៀមប៉ាង អាងត្រពាំងថ្ម តំបន់អភិរក្សសត្វខ្សឹបកំពង់ធំ-សៀមរាប តំបន់ព្រៃការពារសីមា និងតំបន់ព្រៃការពារព្រះវិហារ។

### ៤.២ កសិដ្ឋានចិញ្ចឹម ការបន្ទាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់៩ខែ ដើមឆ្នាំ២០១៥នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាគឺ៖ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន១.១១៣ក្បាល សត្វកើតថ្មីចំនួន៥៥ក្បាល ដោះលែងទៅព្រៃធម្មជាតិវិញចំនួន៩៩៨ក្បាល ព្យាបាលសត្វចំនួន២.៤២២ក្បាល ជួលជុលផ្លូវចំនួន២.២៨០ម២ សាងសង់ទ្រុងសត្វចំនួន២.៥៥០ម២ សាងសង់សំណង់ផ្សេងៗចំនួន២៧០ម២ ដាំដុះកូនឈើលម្អចំនួន១.៣២៨ដើម បណ្ដុះផ្កាចំនួន៣.៤៩៣ដើម កាប់ឆ្ការអនាម័យព្រៃចំនួន១០ហិកតា និងអប់រំផ្សព្វផ្សាយសិស្សនិស្សិតចំនួន៥.៤០៨នាក់

- ក្រុមហ៊ុនចំនួន៦ គ្រប់គ្រងកសិដ្ឋានចំនួន៧ កំពុងចិញ្ចឹមស្វាក្ដាមចំនួន៥៣.៤៣២ក្បាល និងនាំចេញចំនួន១.៩៨១ក្បាល។

### ៤.៣ ការងារសហគមន៍ព្រៃឈើ

- រៀបចំប្រកាសស្ដីពីការបង្កើត និងគ្រប់គ្រងតំបន់ព្រៃសហគមន៍ស្ថិតនៅក្នុងខេត្ត៣ គឺខេត្តបាត់ដំបង ស្ទឹងត្រែង និងខេត្តពោធិ៍សាត់ ក្នុងនោះខេត្តបាត់ដំបង មានចំនួន៦សហគមន៍ព្រៃឈើ ស្មើនឹង២៦កន្លែង មានផ្ទៃដីសរុប៧៨៦ហិកតា ខេត្តស្ទឹងត្រែងមានចំនួន៣សហគមន៍ព្រៃឈើ ស្មើនឹង៣កន្លែង មានផ្ទៃដីសរុប១.៨៣៧ហិកតា និងខេត្តពោធិ៍សាត់ដែលមានចំនួន២៥សហគមន៍ព្រៃឈើ ស្មើនឹង២៦កន្លែង មានផ្ទៃដីសរុប៦.៦៥៥ហិកតា

- ចេញប្រកាសទទួលស្គាល់ស្ដីពីការបង្កើតនិងគ្រប់គ្រងតំបន់ព្រៃសហគមន៍ ក្នុងខេត្តបាត់ដំបងមានចំនួន៨សហគមន៍ព្រៃឈើ មានផ្ទៃដីសរុប១.៣៦៥ហិកតា ខេត្តពោធិ៍សាត់មានចំនួន២៥សហគមន៍ព្រៃឈើ មានផ្ទៃដីសរុប៦.៦៥៥ហិកតា ខេត្តស្ទឹងត្រែងមានចំនួន២សហគមន៍ព្រៃឈើ មានផ្ទៃដីសរុប៦៧៤ហិកតា និងខេត្តស្វាយរៀងមានចំនួន២សហគមន៍ព្រៃឈើ មានផ្ទៃដីសរុប៣៦ហិកតា

- ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍បានចំនួន១៩សហគមន៍ មានផ្ទៃដីទំហំ២០.៦០៧ហិកតា ក្នុងនោះខេត្តក្រចេះ១០សហគមន៍ មានផ្ទៃដី១៧.៧៩៥ហិកតា ខេត្តកំពង់ធំ៣សហគមន៍ មានផ្ទៃដី៧៥០ហិកតា ខេត្តបាត់ដំបង២សហគមន៍ មានផ្ទៃដី៥៧៩ហិកតា និងខេត្តរតនគិរី៤សហគមន៍ មានផ្ទៃដី១.៤៨៣ហិកតា និងបានអនុម័តផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន១៤ ក្នុងនោះខេត្តក្រចេះចំនួន៦សហគមន៍ ខេត្តស្ទឹងត្រែងចំនួន៤សហគមន៍ និងខេត្តកំពង់ធំចំនួន៤សហគមន៍

- បានរៀបចំកិច្ចប្រជុំគណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើថ្នាក់ខេត្ត នៅខេត្តបាត់ដំបង ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដែលមានអ្នកចូលរួមសរុប១២១នាក់ (ស្ត្រី១៤នាក់) និងរៀបចំជ្រើសរើសតំណាងបណ្ដាញសហគមន៍ព្រៃឈើថ្នាក់ខេត្តចំនួន២ គឺខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដែលមានអ្នកចូលរួមសរុប១៣១នាក់ (ស្ត្រី១៦នាក់) ដែលអញ្ជើញមកពីសហគមន៍ព្រៃឈើ

- ចុះផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធការងារសហគមន៍ព្រៃឈើ ផលប្រយោជន៍ព្រៃឈើ និងវិធីសាស្ត្រទប់ស្កាត់បទល្មើសព្រៃឈើដល់សហគមន៍ព្រៃឈើចំនួន៨ នៅខេត្តបន្ទាយមានជ័យ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តក្រចេះ ដែលមានអ្នកចូលរួមសរុប២៧២នាក់ (ស្ត្រី៨១នាក់) មកពីសមាជិកសហគមន៍ព្រៃឈើ គណៈកម្មការសហគមន៍ព្រៃឈើ និងអាជ្ញាធរមូលដ្ឋាន

- កំពុងរៀបចំសេចក្ដីព្រាងសៀវភៅស្ថិតិសហគមន៍ព្រៃឈើឆ្នាំ២០១៥ និងរៀបចំព្រឹត្តិប័ត្រព័ត៌មានសហគមន៍ព្រៃឈើប្រចាំឆមាសទី១ ឆ្នាំ២០១៥។

### ៤.៤ ការងារដាំដើមឈើ

- ការដាំឈើជាចម្ការថ្មីនៅតាមបណ្ដាស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើរបស់រដ្ឋបាលព្រៃឈើចំនួន៣(ស្ថានីយយុនរាម ក្បាលឆាយបានបញ្ចប់ការដាំដុះ និងស្ថានីយអូរបឹងរូងបានបញ្ចប់ការឈូសឆាយនិងបន្តការដាំដុះ) ដោយឈូសឆាយដីព្រៃបានចំនួន៤០៥ហិកតា និងដាំកូនគ្រញូងសរុបចំនួន៣៧០ហិកតា

- ថែទាំចម្ការឈើឆ្នាំទី១ដល់ឆ្នាំទី៥ ដែលមានផ្ទៃដីទំហំ២.៨១៨ហិកតា នៅស្ថានីយដាំឈើចំនួន១៦ និងបានថែទាំភ្លូរ ដាំជួស និងធ្វើអនាម័យ ជាពិសេសគឺទប់ស្កាត់ការរុករានចម្ការឈើ និងភ្លើងឆេះព្រៃ

- បណ្ដុះកូនឈើសម្រាប់ចែកជូនកសិករដាំអាស្រ័យផលបានចំនួន២.៣៤៨.៦៦២ដើម និងចែកជូនប្រជាកសិករដាំចំនួន១.១៨១.២៩២ដើម។

### ៤.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើចំនួន៤ក្រុមហ៊ុន គឺក្រុមហ៊ុនថាច់វ៉ុង(ខេមបូឌា) ខូអិលធីឌី

ក្រុមហ៊ុន ស៊ីវហ្គេក អ៊ិនវេសមេន ក្រុមហ៊ុនដូទីសាយហ្គន ប៊ិញហឿក(អេស ប៊ី ខេ) និងក្រុមហ៊ុន ស៊ុ&វី

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញឈើកែច្នៃជូនក្រុមហ៊ុនចំនួន៥ ដែលមានបរិមាណឈើកែច្នៃគ្រប់ប្រភេទចំនួន ១៣.៤៥៣ម៣ និងដើមចន្ទន៍ក្រស្នា(រុក្ខជាតិរស់)ចំនួន៧២ដើម

-ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលផលិតផលឈើកែច្នៃជូនក្រុមហ៊ុនចំនួន២ ដែលមានបរិមាណឈើកែច្នៃចំនួន៩២៨ម៣

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុនចំនួន៥១ និងអតិថិជនចំនួន១២នាក់ ដែលមានឈើហ៊ុបមូលសរុបចំនួន៧៧.១៩០ម៣ ឈើជ្រងចំនួន៣២៦ម៣ កូនឈើចំនួន១.១១២.៩០៩ដើម អុសចម្រុះចំនួន ១៩៤.៥១០ស្ទែរ ជ័រទឹកចំនួន១.២២៧តោន ផ្តៅចំនួន៣០តោន និងឫស្សីចំនួន៦២៧តោន

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តនិងយានយន្តជូនក្រុមហ៊ុននិងអតិថិជនសរុបចំនួន៨១គ្រឿង ក្នុងនោះ ប្រជាជនក្នុងខេត្តបាត់ដំបងចំនួន២៣គ្រឿង ប្រជាជនក្នុងខេត្តកោះកុងចំនួន៣គ្រឿង និងក្រុមហ៊ុនចំនួន៥៥គ្រឿង

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចេញជូនក្រុមហ៊ុនចំនួន៥ ស្មើនឹង១០៨សន្លឹក ដែលមានបរិមាណឈើកែច្នៃគ្រប់ប្រភេទចំនួន១២.៣៤៥ម៣ កម្ទេចឈើចំនួន៨៩៩តោន និងចន្ទន៍ក្រស្នាចំនួន២៥ដើម

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចូលជូនក្រុមហ៊ុនចំនួន២ ស្មើនឹង១២សន្លឹក ដែលមានបរិមាណឈើកែច្នៃគ្រប់ប្រភេទចំនួន៣៧០ម៣

- ពិនិត្យនិងរៀបចំកំណត់កូតាអនុញ្ញាតឲ្យបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ រោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច និងឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមមានលក្ខណៈឧស្សាហកម្ម និងសិប្បកម្មសម្រាប់ឆ្នាំ២០១៥ជូនខណ្ឌរដ្ឋបាលព្រៃឈើទាំង២១ដើម្បីពិនិត្យនិងសម្រេចក្នុងនោះ៖

÷ បង្កើតរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើធុនតូចចំនួន៧៣៣កន្លែង

÷ បង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើចំនួន៥១៩កន្លែង

÷ ឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើចំនួន១៩កន្លែង។

### ៤.៦ ការងារចំណូលព្រៃឈើ

- សម្រាប់៩ខែ ដើមឆ្នាំ២០១៥នេះចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន១៦.៤៥៩.៣៨២.៣៩០ រៀល និងចំណូលពីសេវាសាធារណៈចំនួន៥.៩៨៥.៦៨៩.៩៨១រៀល និង២៣៤.៤៣៦,៩២ដុល្លារ។

### ៤.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់៩ខែ ដើមឆ្នាំ២០១៥នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃ នៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន១.៦៥៣ករណី ដោយបញ្ជូនទៅតុលាការចំនួន១.១៦៦ករណី និងពិន័យអន្តរការណ៍ចំនួន៤៨៧ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រងចំនួន៦៤៩ម៣ ឈើអារចំនួន៣.៥១៤ម៣ ឈើក្រាក់គ្រញូងចំនួន១០០ម៣ និង៥.៧៩២គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន៣.៨៩៩ក្បាលនិង១.៦៥៩គ.ក្រ អនុផលព្រៃឈើ សម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន២.០៨០ហិកតា ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការ និងដកហូតរណារយន្តចំនួន៤៥២គ្រឿង

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ស្រង់ព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលបានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន៧៩២ករណី ដែលការចុះផ្សាយនេះឆ្លុះបញ្ចាំងពីចំណុចវិជ្ជមានផង និងអវិជ្ជមានផងដែរ និងបានផ្ញើជូនខណ្ឌរដ្ឋបាលព្រៃឈើធ្វើការបំភ្លឺមានចំនួន ១៩៣ករណី ហើយបណ្តាខណ្ឌរដ្ឋបាលព្រៃឈើបានធ្វើការបំភ្លឺមកវិញមានចំនួន៣៤ករណី

- ពិនិត្យ និងផ្ទៀងផ្ទាត់សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ កាប់រានដីព្រៃ និងវត្ថុតាងនៃបទល្មើសព្រៃឈើចំនួន ១៤១ករណី នៅក្នុងខេត្តចំនួន១១ គឺត្បូងឃ្មុំ១០ករណី ក្រចេះ១៩ករណី រតនគិរី១៩ករណី ស្ទឹងត្រែង១៩ករណី មណ្ឌលគិរី ១០ករណី កំពង់ឆ្នាំង៤ករណី ពោធិ៍សាត់១៥ករណី បាត់ដំបង៨ករណី កំពង់ធំ៩ករណី សៀមរាប៩ករណី និងព្រះវិហារ១៩ករណី

- តាមដាននិងជំរុញសំណុំរឿងបទល្មើសព្រៃឈើនៅតុលាការចំនួន១៩៩ករណី នៅក្នុងខេត្តចំនួន១២ គឺព្រៃវែង៤ករណី កំពង់ចាម៤ករណី ត្បូងឃ្មុំ៤ករណី ក្រចេះ៣៣ករណី រតនគិរី៩ករណី ស្ទឹងត្រែង១៥ករណី មណ្ឌលគិរី១៤ករណី កំពង់ធំ៦៧ករណី សៀមរាប១៥ករណី ឧត្តរមានជ័យ១៥ករណី ព្រះវិហារ១៥ករណី និងបន្ទាយមានជ័យ៤ករណី។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីធ្វើអាជីវកម្ម សរុបរយៈពេល៩ខែបានចំនួន១២.២៨៥តោន ស្មើ១០២,៣៨% នៃផែនការ១២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១១.៧១៥តោន (បញ្ចប់រដូវ)

- នេសាទគ្រួសារក្នុងដែននេសាទ ក្នុងខែកញ្ញា អនុវត្តបានចំនួន២០.១០០តោន។ សរុបរយៈពេល៩ខែបានចំនួន២២០.៣៥០តោន ស្មើ៦២,៩៦% នៃផែនការ៣៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន៣៥០តោន

- នេសាទគ្រួសារតាមវាលស្រែ ក្នុងខែកញ្ញា អនុវត្តបានចំនួន១៨.២០០តោន សរុបរយៈពេល៩ខែបានចំនួន៨៧.៣៥៥តោន ស្មើ៥៨,២៤% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន២.៣៥៥តោន។

#### ៥.១.២ នេសាទសមុទ្រ

ក្នុងខែកញ្ញា អនុវត្តបានចំនួន៩.០០០តោន សរុបរយៈពេល៩ខែចំនួន៧៨.០០០តោន ស្មើ៧០,៩១% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន២.០០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា ក្នុងខែកញ្ញា អនុវត្តបានចំនួន១៦.០៥០តោន សរុបរយៈពេល៩ខែបានចំនួន១១២.១០០តោន ស្មើ៧៧,៨៥%នៃផែនការ១៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន៣៧.១០០តោន

- ការចិញ្ចឹមក្រពើ ក្នុងខែកញ្ញា អនុវត្តបានចំនួន១០.០០០ក្បាល សរុបរយៈពេល៩ខែ បានចំនួន១៨៥.៥០០ក្បាល ស្មើ៧៤,២០%នៃផែនការ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន២៩.៥០០ក្បាល

- ការភ្ញាស់កូនត្រីពូជ ក្នុងខែកញ្ញា អនុវត្តបានចំនួនប្រមាណ២០.០០០.០០០កូន សរុបរយៈពេល៩ខែ បានចំនួនប្រមាណ១៤៥.០០០.០០០កូន ស្មើ៨០,៥៦% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួនប្រមាណ១០.០០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៤-២០១៥ ក្នុងខែកញ្ញា អនុវត្តបានចំនួន៣.៥០០តោន សរុបរយៈពេល៩ខែបានចំនួន៤៥.០០០តោន ស្មើ៥៤,៨៨% នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៧.០០០តោន

- ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៥ ក្នុងខែកញ្ញា អនុវត្តបានចំនួន៥០០តោន សរុបរយៈពេល៩ខែបានចំនួន៧.៨០០តោន ស្មើ៩៧,៥០% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន១.៣០០តោន

- ការផលិតទឹកត្រីក្នុងខែកញ្ញា អនុវត្តបានចំនួន៣.០០០.០០០លីត្រ សរុបរយៈពេល៩ខែបានចំនួន៥០.០០០.០០០លីត្រ ស្មើ១០០% នៃផែនការ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៥.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ ក្នុងខែកញ្ញា អនុវត្តបានចំនួន៥០០តោន សរុបរយៈពេល៩ខែបានចំនួន៧.១០០តោន ស្មើ៤៧,៣៣% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១.៩០០តោន

- ផលនេសាទកែច្នៃ ក្នុងខែកញ្ញា អនុវត្តបានចំនួន៣០០តោន សរុបរយៈពេល៩ខែបានចំនួន៣.៧០០តោន ស្មើ៧៤% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១.៣០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- នៅក្នុងរយៈពេល៩ខែដើមឆ្នាំ២០១៥នេះ សំណុំរឿងបទល្មើសជលផលមានចំនួន២.៧៤៤ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន២.៦៥៥ករណី និងបទល្មើសសមុទ្រចំនួន៨៩ករណី

- បានផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន៩៨វគ្គ ដោយមានអ្នកចូលរួមចំនួន៧.៩៩១នាក់ ក្នុងនោះស្ត្រីចំនួន៣.០៣៣នាក់

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមានៈ របាំងស្បៃមុងនិងសាច់អួនប្រវែង១.២៨៨.៣១៩ ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន២៤.១៦៧មាត់ បង្គោល/ចម្រឹងចំនួន១.០៣៩.៥៣២ដើម ឧបករណ៍ឆក់ត្រីចំនួន ១.៣៦២គ្រឿង សម្រាស់ចំនួន៦២.៩៤០ម៉ែត្រក្រឡា របាំងព្រួលប្រវែង១៤.៩៩៨ម៉ែត្រ លបកែច្នៃ(កន្ទុយកណ្ដុរ/ពោះ វៀនជ្រូក)ចំនួន១.៩១៥គ្រឿង លែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន២៣៧.១៧២គ.ក្រ កូនត្រីឆ្តោចំនួន៥៧២.៤៥០ ក្បាល កូនត្រីរ៉ស់ចំនួន១.០៤១.០០០ក្បាល និងកូនត្រីប្រាចំនួន១.០៧០.៥០០កូន

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទ ល្មើសនេសាទតាមគ្រប់រូបភាព រួមទាំងការទប់ស្កាត់ការលួចចិញ្ចឹមត្រីរ៉ស់និងត្រីឆ្តោផងដែរ។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផល មកទល់ពេលនេះសរុបបានចំនួន២.៨១៦.៥៩១.៧៧៥រៀល ស្មើ៧៩,២៥% នៃ ផែនការ៣.៥៥៤.២៨១.២៥០រៀល (សម្រាប់រយៈពេល៩ខែដើមឆ្នាំ) ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើង ចំនួន១៤៩.៧៦២.៥៤៣រៀល។ ដោយឡែក ក្នុងខែកញ្ញា ឆ្នាំ២០១៥ អនុវត្តបានចំនួន៤៦២.០៤០.០០០រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចូលរួមប្រជុំនិងសិក្ខាសាលាផ្សេងៗសរុបចំនួន១១៤លើកនៅក្នុងប្រទេស និង១០លើកនៅក្រៅប្រទេសដូចជា ប្រទេសអូស្ត្រាលី ជប៉ុន ថៃ ភូមា ឥណ្ឌូនេស៊ី អ៊ីតាលី និងឡាវ

- ធ្វើពិសោធន៍ចំនួន១០៣ប្រភេទនៅ៦៧៥កន្លែង ធ្វើអង្កេតបានចំនួន៨ប្រភេទ ដោយបានសម្ភាសន៍ជាមួយ កសិករចំនួន៧០០គ្រួសារ

- ធ្វើទិវាស្រែបង្ហាញនិងបើកវគ្គបណ្ដុះបណ្ដាលកសិករចំនួន៣៦លើក ដែលមានកសិករចូលរួមចំនួន១.៦៦០នាក់ នៅខេត្តតាកែវ ស្វាយរៀង កំពត សៀមរាប កំពង់ឆ្នាំង កែប ព្រះសីហនុ និងខេត្តរតនគិរី

- ធ្វើការបែងចែកឯកសារបោះពុម្ពសរុបចំនួន១១.៦៨៥ច្បាប់

- បន្តអភិរក្សលើដំណាំចំនួន៣១ប្រភេទ ដែលក្នុងនោះរួមមាន ស្រូវចំនួន៦.៦៨៧បញ្ជីក/សំណាក ស្រងែចំនួន ២៩១បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន២៩ប្រភេទមាន៧១១បញ្ជីក/សំណាក សរុបទាំងអស់ចំនួន៧.៦៨៩បញ្ជីក/ សំណាក

- ដឹកនាំនិស្សិតស្រាវជ្រាវនិងសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របានចំនួន២២នាក់ មកពីសាកលវិទ្យាល័យ ភូមិន្ទកសិកម្ម

- ចូលរួមវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា និងសន្និបាតក្នុងប្រទេសចំនួន០៤លើក ដែលមានមន្ត្រីចូលរួមសរុប ចំនួន០៥នាក់ និងក្រៅប្រទេសចំនួន៣២លើក ដែលមានថ្នាក់ដឹកនាំនិងមន្ត្រីចូលរួមចំនួន៤៤នាក់ ហើយមន្ត្រី និងនិយោជិត សរុបចំនួន៤រូបបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិតក្រៅប្រទេស

- ការស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មក្នុងគេហទំព័រ www.cardi.org.kh និង www.crkb.org.kh សម្រាប់ រយៈពេល៩ខែ ដើមឆ្នាំ២០១៥នេះ មានអ្នកចូលរួមសរុបចំនួន៣០៥.៦៩៧នាក់ គិតជាមធ្យមប្រមាណ១.១៣២នាក់ក្នុង មួយថ្ងៃ ។

## ៧ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៣៦២ច្បាប់ (សរុបរយៈពេល៩ខែចំនួន៤.០៣៩ច្បាប់) ទទួលពីអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៣៥៩ច្បាប់ (សរុបរយៈពេល៩ខែចំនួន៣.១០៥ច្បាប់) និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន១៤៤ច្បាប់ (សរុបរយៈពេល៩ខែចំនួន១.១៤៨ច្បាប់) និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៧២៦ច្បាប់ (សរុបរយៈពេល៩ខែចំនួន៦.៥៧៣ច្បាប់) ប្រកាស សេចក្ដីសម្រេច និងសារាចរ ក្នុងខែចំនួន៦២ច្បាប់ (សរុបរយៈពេល ៩ខែចំនួន៥១១ច្បាប់) ចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៣០ច្បាប់ (សរុបរយៈពេល៩ខែចំនួន២៥២ច្បាប់)

និងផ្តល់ទិដ្ឋាការបេសកកម្មចំនួន៦២៨ច្បាប់ សរុបមនុស្ស១.១៧៩នាក់

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ។ល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៦៤០នាក់ នារីចំនួន១.៣៥១នាក់ ស្មើនឹង២០%រួមមាន៖

+ អង្គភាពថ្នាក់កណ្តាលចំនួន៤.០៥២នាក់ ក្នុងនោះនារីចំនួន៧៧៩នាក់ ស្មើនឹង១៩%

+ អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៥៨៨នាក់ ក្នុងនោះនារីចំនួន៥៧២នាក់ ស្មើនឹង២២%

- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន៦៦នាក់ ក្នុងនោះបោះបង់ចោលការងារចំនួន២០នាក់ សុំលាឈប់ពីការងារចំនួន២៧នាក់ និងមរណភាពចំនួន១៩នាក់

- ចេញច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន៤៩នាក់ ច្បាប់ព្យាបាលជំងឺចំនួន២៣នាក់ និងច្បាប់សម្រាកមាតុភាពចំនួន២១នាក់

- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន១២នាក់ ផ្ទេរចូលក្រសួងចំនួន០៦នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន៦៤នាក់

- ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន១៩៨នាក់ និងចូលបម្រើការងារវិញចំនួន៤០នាក់

- បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន២៥៩នាក់ និងក្នុងប្រទេសចំនួន៧៧នាក់

- បានរៀបចំការប្រឡងជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ឆ្នាំ២០១៥ ចំនួន២៧៧នាក់

- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ៩ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- មន្ត្រីចំនួន១៨០រូបបានចូលរួមសិក្ខាសាលាស្តីពីវិស័យកសិកម្មកម្ពុជា ការត្រៀមជាស្រេចសម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ាន និងតទៅអនាគត

- បានបញ្ជូនមន្ត្រីចូលរួមសិក្ខាសាលា និងកិច្ចប្រជុំក្នុងប្រទេសសរុបចំនួន៧៨រូប ដូចជាសិក្ខាសាលាស្តីពីកម្រិតកាកសំណល់ជាតិពុល កិច្ចប្រជុំលើកទី១៩នៃក្រុមការងារជំនាញស្តីពីការធ្វើសុខដុមនីយកម្មកម្រិតកាកសំណល់ជាតិពុលនៃថ្នាំកសិកម្ម កិច្ចប្រជុំលើកទី៦របស់ក្រុមការងារជំនាញស្តីពីការអនុវត្តកសិកម្មល្អ កិច្ចប្រជុំថ្នាក់តំបន់និងអន្តរជាតិរបស់ក្រុមការងារបច្ចេកទេសក្រពើ កិច្ចប្រជុំរបស់មជ្ឈមណ្ឌលអាស៊ានសម្រាប់ក្រុមប្រឹក្សាអភិវឌ្ឍន៍សហគន៍កសិកម្មលើកទី២២ និងកិច្ចប្រជុំលើកទី១៧ របស់ក្រុមការងារអាស៊ានស្តីពីសហគមន៍កសិកម្ម

- បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទទៅចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាសរុបចំនួន៣២៩រូប នៅប្រទេសចំនួន៣០

- រៀបចំលិខិតជូនក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំលិខិតឆ្លងដែនចំនួន២៣ច្បាប់ ពន្យារទិដ្ឋាការស្នាក់នៅជូនក្រុមអ្នកបច្ចេកទេសចិនចំនួន២៣រូប

- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយគ្រប់ដៃគូ ទាំងអង្គការជាតិ-អន្តរជាតិ និងបណ្តាប្រទេសផ្តល់ជំនួយពាក់ព័ន្ធទាំងអស់ក្នុងវិស័យកសិកម្ម។

## ១០ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបចំនួន១.២២៣នាក់ (ស្ត្រី៣៩៦នាក់) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាចំនួន១.០១៥នាក់(ស្ត្រី៣៤៦នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន២០៨នាក់(ស្ត្រី៤៦នាក់) ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិង

អភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម និងកសិឧស្សាហកម្ម។ បន្តសហការជាមួយក្រសួងអប់រំ យុវជននិងកីឡាក្នុងការកែលម្អកម្មវិធីសិក្សាក្នុងគោលបំណងប្រែក្លាយសាលាជាតិកសិកម្មព្រែកលៀបទៅជាសាកល វិទ្យាល័យជាតិកសិកម្មព្រែកលៀប រៀបចំកែលម្អបទបញ្ជាផ្ទៃក្នុង ពិសោធន៍ដំណាំស្រូវជប៉ុន និងបញ្ជូនគ្រូចំនួន៧០នាក់ ដើម្បីបន្តចុះសិក្សាស្រាវជ្រាវតាមផ្នែកសំខាន់ៗនៅ១៥ ខេត្ត-រាជធានី។ សាលាជាតិបាននិងកំពុងបំពាក់ប្រព័ន្ធអ៊ីនធឺណែត និងដំឡើងស៊ើវើ(Sever) ព្រមទាំងសហការយ៉ាងជិតស្និទ្ធជាមួយភាគីចិនក្នុងការសាងសង់អគារមន្ទីរពិសោធន៍អំណោយ របស់សាធារណរដ្ឋប្រជាមានិតចិនដែលគ្រោងនឹងបញ្ចប់នៅចុងឆ្នាំនេះ។

**១០.២ សាលាជាតិកសិកម្មកំពង់ចាម**

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបមានចំនួន១.៧១៨នាក់(ស្ត្រី៤៥៨នាក់) រួមមានៈ

- និស្សិតអាហារូបករណ៍សរុប៨៤៨នាក់ (ស្ត្រី៣៨១នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៦៩០នាក់ (ស្ត្រី២៨១នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម១៥៨នាក់(ស្ត្រី១០០នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃ២២៨នាក់ (ស្ត្រី៦៧នាក់) ថ្នាក់បរិញ្ញាចំនួន២១៧នាក់(ស្ត្រី៦៦នាក់) និងថ្នាក់បរិញ្ញារង ចំនួន១១នាក់ (ស្ត្រី១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។

**១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

និស្សិតកំពុងសិក្សាមានចំនួនសរុប៥.៩៧៧នាក់(ស្ត្រី១.៤០០នាក់) ចែកចេញជា១០មហាវិទ្យាល័យ គឺមហា វិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រ ជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិង រដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមដើម្បីបណ្តុះបណ្តាលលើ កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ សាកលវិទ្យាល័យចាប់ផ្តើមបវេសនកាលឆ្នាំសិក្សាថ្មីឆ្នាំ២០១៥-២០១៦ ហើយទទួលសិស្សថ្នាក់ទី១២ ទើបប្រឡង សញ្ញាបត្រទុតិយភូមិរួចថ្មីៗចំនួន១៥០នាក់មកធ្វើទស្សនកិច្ចសិក្សាស្វែងយល់ អំពីការសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្មដែលរៀបចំដោយ CJCC។ ប្រារព្ធពិធីសំណេះសំណាលជូនដំណើរ ដល់និស្សិតឆ្នាំទី៣ចំនួន១០២នាក់ ដែលត្រូវចេញដំណើរទៅធ្វើកម្មសិក្សារយៈពេល១១ខែ នៅប្រទេសអ៊ីស្រាអែល។ សហការជាមួយសាកលវិទ្យាល័យ រដ្ឋមីស៊ីហ្គែន នៃសហរដ្ឋអាមេរិក ក្នុងការបើកវគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃ គម្រោងកម្មវិធីជូនដល់មន្ត្រីរាជការនិងបុគ្គលិក អង្គការពាក់ព័ន្ធ និងសហការជាមួយស្ថានទូតអង់គ្លេស ដើម្បីផ្សព្វផ្សាយ អាហារូបករណ៍ទៅសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់ និងបណ្ឌិតនៅប្រទេសអង់គ្លេស ជូនដល់និស្សិតសាកលវិទ្យាល័យភូមិន្ទ កសិកម្ម។ សាកលវិទ្យាល័យបានចុះហត្ថលេខាលើអនុស្សរណៈលើកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ Shinji ប្រទេសជប៉ុន និងប្រជុំជាមួយគណៈប្រតិភូចលនាភូមិថ្មីរបស់កូរ៉េ ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងការ អនុវត្តកម្មវិធីចលនាភូមិថ្មីនៅក្នុងប្រទេសកម្ពុជា។

គ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើ តែងតែបញ្ជូននិស្សិតឱ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញ នៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដូចខែមុនៗដែរដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការ បង្ហាត់ឱ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិពាណិជ្ជកម្ម រួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូ ឱ្យកាន់តែទូលំទូលាយ។

**១១ ការងារយេនឌ័រ**

ក្នុងរយៈពេល០៩ខែឆ្នាំ២០១៥នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបើកវគ្គបណ្តុះបណ្តាលចំណេះ ដឹងយេនឌ័រ និងផ្សព្វផ្សាយពីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងលើស្ត្រីភេទជូនដល់ថ្នាក់ក្រោមជាតិ គឺ មន្ត្រីក្នុងមន្ទីរកសិកម្មខេត្តកំពង់ចាម ដោយរួមបញ្ចូលមន្ត្រីថ្នាក់ស្រុកទាំង១០ស្រុក ក្នុងមន្ទីរសរុបចំនួន៥៣នាក់ ក្នុងនោះ មានស្ត្រីចំនួន២១នាក់។ ទន្ទឹមនឹងនោះ ក្រសួងក៏បានត្រៀមចុះទៅបើកវគ្គបណ្តុះបណ្តាលពីយេនឌ័រនិងផ្សព្វផ្សាយពីអនុ សញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទនៅខេត្តបាត់ដំបងបន្តទៀតក្នុងឆ្នាំ២០១៥នេះ ព្រមទាំងធ្វើ បច្ចុប្បន្នភាពគោលនយោបាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មឆ្នាំ២០១៤-២០១៨។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួម នៅក្នុងរយៈពេល៩ខែដើមឆ្នាំ២០១៥នេះ ដំណើរការការងារបង្កបង្កើនផលស្រូវរដូវវស្សានៅទូទាំងប្រទេស សម្រេចបានចំនួន២.៤៤៦.៧៥៥ហិកតា ស្មើនឹង៩៥,៣១% នៃផែនការ២.៥៦៧.១៣០ហិកតា (លើសឆ្នាំមុន២៦.៣០៦ ហិកតា គិតក្នុងរយៈពេលដូចគ្នា)។ ខេត្តចំនួន១០ ត្រូវបានបញ្ចប់ការងារដាំដុះស្រូវរដូវវស្សាតាមផែនការដែលបានគ្រោងទុកដូចបានរៀបរាប់ខាងលើ។ មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយល្អនៅទូទាំងប្រទេស តែនៅតាមតំបន់ខ្លះក៏ពុំទាន់មានទឹកដក់គ្រប់គ្រាន់នៅឡើយ ដោយសារការប្រែប្រួលធាតុអាកាស និងមានភ្លៀងធ្លាក់នៅចុងរដូវ។ ឆ្នាំនេះ ប្រជាកសិករចូលចិត្តបង្កបង្កើនផលស្រូវ ដោយព្រោះយកតែម្តងច្រើនជាងការដកស្ទូង ម្យ៉ាងមកពីការរាំងស្ងួតអូសបន្លាយយូរនៅដើមរដូវ និងដោយសារខ្វះកម្លាំងពលកម្មផងដែរ។

ពាក់ព័ន្ធនឹងជំងឺ ជ្រូកត្រចៀកខៀវ(Porcine Reproductive Respiratory Syndrome: PRRS) ដែលកើតមានឡើងនៅខេត្តសៀមរាប កំពង់ចាម ព្រៃវែង និងខេត្តស្វាយរៀងនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសកំណត់តំបន់ផ្ទុះជំងឺនិងបានចាត់អង្គភាពជំនាញនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលសហការជាមួយមន្ត្រីបសុពេទ្យខេត្ត ស្រុក និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីចាត់វិធានការជីវសុវត្ថិភាព និងបន្តតាមដានត្រួតពិនិត្យនៅតាមតំបន់ដែលផ្ទុះជំងឺ ដោយបាញ់ថ្នាំសម្លាប់មេរោគបានទាន់ពេលវេលា ដើម្បីទប់ស្កាត់ការឆ្លងរាលដាលទៅកន្លែងដទៃទៀត។ មកទល់ពេលនេះ ស្ថានភាពជំងឺស្ទើតែបាត់ទាំងស្រុងហើយ។ សូមអនុញ្ញាតជម្រាបជូនថា ជំងឺជ្រូកត្រចៀកខៀវនេះគឺពុំមានឆ្លងរាលដាលទៅដល់មនុស្សទេ។ ទោះជាយ៉ាងណា ក្រសួងនៅតែបន្តចាត់វិធានការតាមគ្រប់រូបភាពដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺជ្រូកត្រចៀកខៀវ ដូចជា ធ្វើការផ្សព្វផ្សាយណែនាំដល់កសិករ ភ្នាក់ងារសុខភាពសត្វភូមិ និងអាជ្ញាធរភូមិ-ឃុំ អំពីផលប៉ះពាល់នៃជំងឺឆ្លងសត្វ វិធានការការពារ និងត្រូវផ្តល់ព័ត៌មានពីសត្វឈឺឬងាប់នៅក្នុងមូលដ្ឋានដែលផ្ទុះជំងឺដល់មន្ត្រីបសុពេទ្យស្រុក-ខេត្ត ឬតាមរយៈប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍របស់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ដើម្បីចុះអន្តរាគមន៍ទាន់ពេលវេលា។

ចំពោះការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល គឺស្ថិតនៅតែជាប្រធានបទអាទិភាព ដែលអង្គភាពជំនាញជាសេនាធិការនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែងដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាពពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ លើសពីនេះទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់តាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មជី-ថ្នាំកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ :

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗនិងជំរុញការងារបង្កបង្កើនផលរដូវវស្សានេះឱ្យបានសម្រេចតាមផែនការ
- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា
- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ដើម្បីស្តារការដាំដុះឡើងវិញឱ្យបានទាន់ពេលវេលានៅតំបន់ដែលទទួលរងការខូចខាតដោយគ្រោះរាំងស្ងួត ព្រមទាំងត្រៀមបម្រុងគ្រាប់ពូជស្រូវសម្រាប់ផ្តល់ជូនកសិករក្រីក្រដែលពុំមានលទ្ធភាពទិញគ្រាប់ពូជ ជាពិសេសចំពោះខេត្តដែលមានអតុល្យភាពស្បៀង (អង្ករ) ដោយជំរុញកសិករឱ្យធ្វើការដាំដុះស្រូវស្រាលឬស្រូវកណ្តាល ដើម្បីកាត់បន្ថយផលប៉ះពាល់បង្កដោយគ្រោះរាំងស្ងួត គ្រោះខ្វះទឹកដែលអាចកើតឡើងជាយថាហេតុនៅចុងរដូវ និងដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ/

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តស្រាវជ្រាវការដាំដុះសាកល្បងក្លូនកៅស៊ូប្រភេទ "Invitro" និងបន្តផ្សព្វផ្សាយអំពីបច្ចេកទេសដ៏មានសារសំខាន់នេះក្នុងក្របខណ្ឌនៃគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា

- ការត្រៀមលក្ខណៈដើម្បីរៀបចំកិច្ចប្រជុំ និងសន្និសីទកៅស៊ូប្រចាំឆ្នាំ២០១៥ របស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ។

**២ ផ្នែកផលិតកម្មនិងបសុព្យាបាល** :

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺផ្តាសាយបក្សី ជំងឺជ្រូកត្រចៀកខៀវ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣ ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារ

ព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២។

**៤ ផ្នែកជលផល** :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៥ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ។ ទន្ទឹមនឹងនេះ ក៏បានគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អនុក្រឹត្យ គោលនយោបាយ ផែនការ យុទ្ធសាស្ត្រ ស្តង់ដារ គោលការណ៍ និងហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលកម្ម មានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្ម មានផលិតភាពខ្ពស់និងផលិតសម្រាប់ធ្វើពាណិជ្ជកម្មក្នុងការត្រៀមលក្ខណៈសមាហរណកម្មចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំ២០១៥ និងនាពេលអនាគត៕

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

វេង សាខុន